ក្រសួងអប់រំ យុវជន និងកីឡា

# បរិស្ថាន

# និង ការប្រែប្រួលអាកាសធាតុ

ថ្នាក់ទី ៥



នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា

ឆ្នាំ២០២២

# បរិស្ថាន

# និង ការប្រែប្រួលអាកាសធាតុ

ថ្នាក់ទី ៩

នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា
ឆ្នាំ២០២២

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខៈ ១៤៧ អយក.ប្រក

# ប្រកាស
# ស្តីពី
# ការអនុញ្ញាតឱ្យបោះពុម្ពផ្សាយ
# សៀវភៅបរិស្ថាន និងការប្រែប្រួលអាកាសធាតុ
# ថ្នាក់ទី៤ ថ្នាក់ទី៥ និងថ្នាក់ទី៦

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រម លេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃ២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រម លេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញ ព្រះរាជក្រម លេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញ អនុក្រឹត្យ លេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញ អនុក្រឹត្យ លេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងសេចក្តីសម្រេចលេខ ១១ អយក.សសរ. ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីប្រព័ន្ធអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស
- យោងលិខិតលេខ ១២៦ អគ.អរ ស្តីពី សំណើសុំការអនុញ្ញាតអនុម័តលើ «កម្មវិធីសិក្សាការអប់រំស្តីពីការប្រែប្រួលអាកាសធាតុសម្រាប់បឋមសិក្សា ថ្នាក់ទី៤-៦» «សៀវភៅបរិស្ថាន និងការប្រែប្រួលអាកាសធាតុ ថ្នាក់ទី៤ ថ្នាក់ទី៥ និងថ្នាក់ទី៦» «សៀវភៅហ្វឹកហាត់ បរិស្ថាន និងការប្រែប្រួលអាកាសធាតុ ថ្នាក់ទី៤ ថ្នាក់ទី៥ និងថ្នាក់ទី៦» និង «ឯកសារណែនាំបង្រៀនបរិស្ថាន និងការប្រែប្រួលអាកាសធាតុ ថ្នាក់ទី៤ ថ្នាក់ទី៥ និងថ្នាក់ទី៦» ចុះថ្ងៃព្រហស្បតិ៍ ១៤កើត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី១១ ខែសីហា ឆ្នាំ២០២២ របស់អគ្គនាយកដ្ឋានអប់រំ
- យោងលិខិតលេខ ១១៨ អកស ស្តីពី សំណើសុំការអនុញ្ញាតអនុម័តលើ «កម្មវិធីសិក្សាការអប់រំស្តីពីការប្រែប្រួលអាកាសធាតុសម្រាប់បឋមសិក្សា ថ្នាក់ទី៤-៦» «សៀវភៅបរិស្ថាន និងការប្រែប្រួលអាកាសធាតុ ថ្នាក់ទី៤ ថ្នាក់ទី៥ និងថ្នាក់ទី៦» «សៀវភៅហ្វឹកហាត់ បរិស្ថាន និងការប្រែប្រួលអាកាសធាតុ ថ្នាក់ទី៤ ថ្នាក់ទី៥ និងថ្នាក់ទី៦» និង «ឯកសារណែនាំបង្រៀនបរិស្ថាន និងការប្រែប្រួលអាកាសធាតុ ថ្នាក់ទី៤ ថ្នាក់ទី៥ និងថ្នាក់ទី៦» ចុះថ្ងៃពុធ ១៣កើត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី១០ ខែសីហា ឆ្នាំ២០២២ របស់នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា

## សម្រេច

**ប្រការ១.**_ អនុញ្ញាតឱ្យបោះពុម្ពផ្សាយ **«សៀវភៅបរិស្ថាន និងការប្រែប្រួលអាកាសធាតុ ថ្នាក់ទី៤ ថ្នាក់ទី៥ និង ថ្នាក់ទី៦»** ដែលជាស្នាដៃនិពន្ធរបស់គណៈកម្មការនិពន្ធនៃនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ដើម្បីប្រើប្រាស់ជាឯកសារជំនួយសម្រាប់គ្រូ និងសិស្ស ក្នុងការបង្រៀន និងរៀន ការអប់រំស្តីពីការប្រែប្រួលអាកាសធាតុ នៅកម្រិតបឋមសិក្សាទូទាំងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ២.**_ អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា នាយកដ្ឋានបឋមសិក្សា មន្ទីរអប់រំ យុវជន និង កីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ សាលាបឋមសិក្សា មានភារកិច្ចអនុវត្តប្រកាសនេះ។/

ថ្ងៃ ... ខែ ... ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែសីហា ឆ្នាំ២០២២

**កន្លែងទទួល៖**

- គ្រប់សាលារាជធានីខេត្ត
- គ្រប់អគ្គនាយកដ្ឋាន និងអគ្គាធិការដ្ឋាន
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"
- ដូចប្រការ២ "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

# បុព្វកថា

រាជរដ្ឋាភិបាលបាននិងកំពុងយកចិត្តទុកដាក់ដោះស្រាយបញ្ហាប្រឈមនានា ក្នុងគោលដៅសម្រេចឱ្យបាននូវការអភិវឌ្ឍប្រកបដោយចីរភាព។ ការគ្រប់គ្រងបរិស្ថាន និងការប្រែប្រួលអាកាសធាតុ គឺជាបញ្ហាអាទិភាពមួយសម្រាប់ចីរភាពនៃកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍសង្គមកម្ពុជា ។

ក្រោមកិច្ចសហប្រតិបត្តិការ ជាមួយអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍដោយចីរភាព និងក្រសួងបរិស្ថាន ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំឯកសារ ការអប់រំស្តីពីការប្រែប្រួលអាកាសធាតុសម្រាប់បឋមសិក្សា ថ្នាក់ទី៤ ថ្នាក់ទី៥ និងថ្នាក់ទី៦ ដើម្បីជាឯកសារជំនួយសម្រាប់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សយកទៅអនុវត្ត ក្នុងសកម្មភាពបង្រៀននិងរៀន នៅតាមសាលាបឋមសិក្សា ។ កិច្ចខិតខំប្រឹងប្រែង និងសមិទ្ធផលទាំងនេះ គឺជាការឆ្លើយតបទៅនឹងកម្មវិធីសិក្សា ផែនការសកម្មភាពរបស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីការប្រែប្រួលអាកាសធាតុ ឆ្នាំ២០១៤ - ២០១៨ ព្រមទាំងរួមចំណែកដ៏សំខាន់មួយ ដល់ការធ្វើឱ្យសម្រេចនូវអភិក្រមរបស់រាជរដ្ឋាភិបាលកម្ពុជាផងដែរ។

ក្នុងនាមក្រសួងអប់រំ យុវជន និងកីឡា ខ្ញុំសូមកោតសរសើរដល់ក្រុមការងារអ្នកនិពន្ធ នៃនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា អ្នកបច្ចេកទេស និងអ្នកពាក់ព័ន្ធ ដែលបានអភិវឌ្ឍឯកសារដ៏មានសារៈសំខាន់នេះ។ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា និងក្រុមការងារបច្ចេកទេសនៃនាយកដ្ឋានប្រែប្រួលអាកាសធាតុ នៃក្រសួងបរិស្ថាន ដែលបានជួយឧបត្ថម្ភ គាំទ្រទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ ដល់ការអនុវត្តគម្រោងបញ្ជ្រាបការប្រែប្រួលអាកាសធាតុ និងបង្កើនភាពធន់ក្នុងវិស័យអប់រំ។

ក្រសួងអប់រំ យុវជន និងកីឡាសង្ឃឹមថា ឯកសារ "ការអប់រំស្តីពីការប្រែប្រួលអាកាសធាតុសម្រាប់បឋមសិក្សា ថ្នាក់ទី៤ ថ្នាក់ទី៥ និងថ្នាក់ទី៦" នឹងក្លាយជាឯកសារជំនួយដ៏មានសារៈសំខាន់មួយ ដែលត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយក្នុងការបង្រៀន និងរៀន ដើម្បីលើកកម្ពស់ការយល់ដឹងពីបញ្ហាបរិស្ថាន និងការប្រែប្រួលអាកាសធាតុដល់សិស្សានុសិស្ស សំដៅរួមគ្នារកដំណោះស្រាយបញ្ហានានា ដើម្បីកម្ពុជាក្លាយជាប្រទេសបរិស្ថានបៃតង។

ថ្ងៃ ពុធ ៦កើត ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែ ធ្នូ ឆ្នាំ២០២២

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

# បុព្វកថា

ការប្រែប្រួលអាកាសធាតុបាននិងកំពុងក្លាយជាបញ្ហាប្រឈមចម្បងរបស់សកលលោក និងជះឥទ្ធិពលធ្ងន់ធ្ងរដល់សេដ្ឋកិច្ច សង្គម និងការអភិវឌ្ឍប្រកបដោយនិរន្តរភាពនៅកម្ពុជា ដែលទាមទារឱ្យចាត់វិធានការឆ្លើយតបជាបន្ទាន់ និងជាក់ស្តែង។ ការបញ្ជ្រាបចំណេះដឹងអំពីការប្រែប្រួលអាកាសធាតុក្នុងវិស័យអប់រំ និងការវិនិយោគលើការកសាងសមត្ថភាពមនុស្ស គឺជាវិធានការចម្បងមួយស្របតាមគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា ជាអាទិ៍ ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជាឆ្នាំ២០១៤-២០២៣ (CCCSP) យុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលវែងប្រកបដោយអព្យាក្រឹតកាបូន ការអនុវត្តសេដ្ឋកិច្ចបៃតង សកម្មភាពប្រតិបត្តិមេត្រីបរិស្ថានជាពិសេសកម្មវិធីសាលាមេត្រីបរិស្ថាន និងអារាមមេត្រីបរិស្ថានជាដើម។

ក្រសួងបរិស្ថាននិងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព មានសេចក្តីសោមនស្សយ៉ាងក្រៃលែងដែលបានសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា រៀបចំចងក្រងសៀវភៅ «បរិស្ថាននិងការប្រែប្រួលអាកាសធាតុ» នេះឡើងទុកជាឯកសារជំនួយស្មារតីក្នុងការរៀនសូត្រ ការឈ្វេងយល់ ការបង្រៀន និងរៀនរបស់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សនៅតាមសាលារៀនបឋមសិក្សាក្នុងព្រះរាជាណាចក្រកម្ពុជា។ កិច្ចប្រឹងប្រែងចងក្រងឯកសារនេះ ជាសក្ខីភាពមួយនៃការរួមចំណែកដល់ការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល សំដៅលើកកម្ពស់ការអភិវឌ្ឍធនធានមនុស្សផ្នែកបរិស្ថាន ការអភិរក្សជីវៈចម្រុះ កិច្ចគាំពារបរិស្ថាន និងការរស់នៅប្រកបដោយចីរភាព។

សៀវភៅនេះ គឺស្របតាមរបកគំហើញនិងបរិបទថ្មីៗផ្អែកលើវិទ្យាសាស្ត្រពិត វិទ្យាសាស្ត្រសង្គម កំណត់ត្រាថ្នាក់ជាតិ និងអន្តរជាតិ និងមានសង្គតិភាពផ្អែកអក្សរសាស្ត្រជាតិស្របតាមសទ្ទានុក្រមការប្រែប្រួលអាកាសធាតុ ដើម្បីធានាភាពគ្រប់ជ្រុងជ្រោយនៃមូលដ្ឋានចំណេះដឹងស្តីពីការប្រែប្រួលអាកាសធាតុសម្រាប់ជាឧត្តមប្រយោជន៍ដល់ប្រជាជនគ្រប់រូបនិងគ្រប់ជំនាន់។ ខ្លឹមសារសំខាន់ៗមួយចំនួននៃឯកសារនេះក៏បានបញ្ជ្រាបទៅក្នុងកម្មវិធីសិក្សាជាតិ និងសកម្មភាពលើកកម្ពស់ចំណេះដឹងលើវិស័យបរិស្ថានទាំងក្នុងនិងក្រៅប្រព័ន្ធផងដែរ។

ខ្ញុំសូមកោតសរសើរដល់ក្រុមការងារអ្នកនិពន្ធនៃនាយកដ្ឋានអភិវឌ្ឍន៍កម្មវិធីសិក្សានៃក្រសួងអប់រំយុវជន និងកីឡា នាយកដ្ឋានប្រែប្រួលអាកាសធាតុ នៃអគ្គនាយកដ្ឋានគោលនយោបាយនិងយុទ្ធសាស្ត្រ ក្រសួងបរិស្ថាន និងអ្នកពាក់ព័ន្ធដទៃទៀត ជាពិសេសកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា ដំណាក់កាលទី៣ (CCCA3) ដែលរួមគ្នារៀបចំឯកសារដ៏មានតម្លៃនេះឱ្យកើតចេញជារូបរាង។

ខ្ញុំសូមលើកទឹកចិត្តដល់បណ្តាគ្រឹះស្ថានអប់រំ និងអ្នកប្រើប្រាស់ទាំងអស់ ចាត់ទុកឯកសារនេះ ជាមូលដ្ឋានចំណេះដឹងសម្រាប់ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុឱ្យបានទូលំទូលាយ គ្រប់ជ្រុងជ្រោយ និងមានប្រសិទ្ធភាពខ្ពស់។

ថ្ងៃព្រហស្បតិ៍ ៣កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២២

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**និងជាប្រធានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព**

**សាយ សំអាល់**

# អារម្ភកថា

កុមារា កុមារី ជាទីមេត្រី !

សៀវភៅបរិស្ថាននិងការប្រែប្រួលអាកាសធាតុថ្នាក់ទី៦នេះ ត្រូវបានរៀបចំចងក្រងឡើងដោយគណៈកម្មការនិពន្ធរបស់ក្រសួងអប់រំ យុវជន និងកីឡា ដោយមានការគាំទ្រពីកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា Cambodia Climate Change Alliance។

សៀវភៅនេះ ចងក្រងឡើងក្នុងគោលបំណងធ្វើឱ្យកុមារបានសិក្សា យល់ដឹងពីសារៈសំខាន់នៃការថែរក្សាបរិស្ថាន ដើម្បីជាប្រយោជន៍ដល់ការរស់នៅក្នុងសហគមន៍ ក៏ដូចជាការសិក្សារៀនសូត្រនៅតាមសាលារៀន។ កុមារក៏នឹងបានសិក្សាយល់ដឹងផងដែរអំពីការប្រែប្រួលអាកាសធាតុ ដែលជាកត្តាបង្កគ្រោះមហន្តរាយដល់ការរស់នៅ។ ក្រោយពីទទួលបានចំណេះដឹងទាំងនេះ កុមារនឹងមានទឹកចិត្តចូលរួមធ្វើឱ្យមានបរិស្ថានល្អនៅក្នុងសហគមន៍ និងនៅក្នុងសាលារៀន ជាពិសេសធ្វើឱ្យសាលារៀនក្លាយជាសាលារៀនពណ៌បៃតង ដែលជាការចង់បានរបស់ក្រសួងអប់រំ យុវជន និងកីឡា ក៏ដូចជាក្រសួងបរិស្ថាន។ ការថែរក្សាបរិស្ថានបានក៏ជាកត្តាកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងកាត់បន្ថយគ្រោះមហន្តរាយផងដែរ។

សៀវភៅនេះ មានខ្លឹមសារសំខាន់ៗ ដែលធ្វើឱ្យសិស្សានុសិស្សទាំងឡាយរីករាយក្នុងការសិក្សា។ ខ្លឹមសារទាំងនោះរួមមាន បរិស្ថានសាលារៀន បរិស្ថានសហគមន៍ ការប្រែប្រួលអាកាសធាតុ ការត្រៀមទប់ទល់ជាមួយគ្រោះមហន្តរាយ។ល។ លើសពីនេះទៀត កុមារក៏នឹងទទួលបានការរីករាយផងដែរជាមួយនឹងសកម្មភាពរៀននិងបង្រៀនដូចជា ការពិភាក្សា ការលេងល្បែងសិក្សា ការសិក្សាស្រាវជ្រាវ ការសួរឆ្លើយ ជជែកដេញដោល ដើម្បីធ្វើឱ្យមានគំនិតច្នៃប្រឌិត។

យើងខ្ញុំសង្ឃឹមថា ឯកសារនេះនឹងបានជួយដល់មន្ត្រីអប់រំ អ្នកពាក់ព័ន្ធនានា ជាពិសេសគ្រូបង្រៀនក្នុងការបង្រៀនអំពីបរិស្ថាននិងការប្រែប្រួលអាកាសធាតុ ប្រកបដោយប្រសិទ្ធភាពនិងគុណភាព។ ការរៀបចំចងក្រងឯកសារនេះ ពិតជានៅមានការខ្វះខាតមិនខាន ដូច្នេះយើងខ្ញុំរង់ចាំទទួលមតិកែលម្អពីគ្រប់មជ្ឈដ្ឋាន។

**គណៈកម្មការនិពន្ធ**

## គណៈកម្មការគ្រប់គ្រង

ឯកឧត្តម បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

ឯកឧត្តម បណ្ឌិត **អ៊ឹមកុច**

លោកជំទាវ **ទន់ សារ៉ឹម**

ឯកឧត្តម **ពុត សាមិត្ត**

ឯកឧត្តម **ម៉ុក សារ៉ុម**

លោក **ស៊ុន ប៊ុណ្ណា**

លោកបណ្ឌិត **ហាក់ ម៉ៅ**

## គណៈកម្មការដឹកនាំនិងត្រួតពិនិត្យ

លោក ស៊ុន ប៊ុណ្ណា

លោក វ៉ា វុទ្ធី

លោក ឃឹម សារិន

លោក យិន ធី

លោក លឹម សុត្ថារិទ្ធ

លោក ព្រំ វិបុល

លោក យ៉ង់ កំស៊ាន្ត

លោកបណ្ឌិត ហៃ ចន្ទី

លោក អ៊ុង សារ៉ាត់

## គណៈកម្មការនិពន្ធ

លោក ឡេង សារី

លោក ស៊ុយ ប៊ុនធឿន

លោក អ៊ឹង សុខា

លោកស្រី ហ៊ូ ច័ន្ទសារ៉ា

**លោក ឈាង ចំរើន**

លោកស្រី ហួ ឆៃរ័ត្ន

## គណៈកម្មការរៀបចំនិងរចនា

លោក លឹម សុត្ថារិទ្ធ

លោកស្រី មឿង ចាន់ផល្លី

លោក ឈាង ចំរើន


**បោះពុម្ពលើកទី១**

**ឆ្នាំ២០២២**

# បញ្ជីអត្ថបទ


ទំព័រ

**បុព្វកថា**........................................................................................i

**អារម្ភកថា**......................................................................................iii

**ជំពូកទី១ ធនធានធម្មជាតិ**........................................................................ 1

មេរៀនទី១ ធនធានធម្មជាតិ........................................................................ 2

មេរៀនទី២ ជីវៈចម្រុះនិងប្រព័ន្ធអេកូឡូស៊ី........................................................ 2

មេរៀនទី៣ ការថែរក្សាធនធានធម្មជាតិ........................................................ 6

**ជំពូកទី២ កិច្ចគាំពារបរិស្ថាន**........................................................................ 17

មេរៀនទី១ ថាមពលកើតឡើងវិញ........................................................................ 18

មេរៀនទី២ ថាមពលអគ្គិសនី........................................................................ 19

មេរៀនទី៣ ការសន្សំសំចៃទឹក........................................................................ 22

មេរៀនទី៤ សំណល់រឹង........................................................................ 26

មេរៀនទី៥ សំណល់រាវ........................................................................ 34

**ជំពូកទី៣ ការរស់នៅប្រកបដោយចីរភាព**........................................................ 39

មេរៀនទី១ អនាម័យតាមទីសាធារណៈ........................................................ 40

មេរៀនទី២ ជំងឺបណ្ដាលមកពីកង្វក់បរិស្ថាន........................................................ 44

**ជំពូកទី ១**

# ធនធានធម្មជាតិ



- ធនធានធម្មជាតិ
- ជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ី
- ការថែរក្សាធនធានធម្មជាតិ

# មេរៀនទី ១ ធនធានធម្មជាតិ

បន្ទាប់ពីបានសិក្សាមេរៀននេះរួច អ្នកសិក្សានឹង៖

- ប្រាប់ពីនិយមន័យនៃធនធានធម្មជាតិ
- ពណ៌នាពីធនធានធម្មជាតិដែលមាននៅក្នុងសាលារៀនឬសហគមន៍
- កំណត់បានពីធនធានធម្មជាតិកកើតឡើងវិញនិងមិនកកើតឡើងវិញ
- យល់ថាធនធានធម្មជាតិមានប្រយោជន៍ចំពោះជីវភាពរស់នៅ
- ស្រឡាញ់ និងចូលរួមការពារធនធានធម្មជាតិនៅក្នុងសាលារៀន និងសហគមន៍។

**១- ចូរសង្កេតមើលរូបខាងក្រោម តើរូបភាពទាំងនេះបង្ហាញពីអ្វី? តើធនធានធម្មជាតិមានន័យដូចម្ដេច? មានអ្វីខ្លះ?**

*ធនធានធម្មជាតិ គឺជាធនធានដែលកើតឡើងពីធម្មជាតិដោយគ្មានសកម្មភាពមនុស្សជាអ្នកបង្កើតមាន ដូចជា ទឹក ដី រ៉ែ ព្រៃឈើ ពន្លឺព្រះអាទិត្យ បរិយាកាសខ្យល់ និងសត្វមានជីវិតទាំងអស់លើភពផែនដី។*













*ធនធានធម្មជាតិនៅលើផែនដី*

## ២- តើធនធានធម្មជាតិចែកចេញជាប៉ុន្មានប្រភេទ ? មានអ្វីខ្លះ ? ចូររៀបរាប់។




ធនធានធម្មជាតិមាន២ប្រភេទគឺ ធនធានកើតឡើងវិញនិងធនធានមិនកើតឡើងវិញ។ ធនធានកើតឡើងវិញរួមមាន ពន្លឺព្រះអាទិត្យ ខ្យល់ ទឹក ដី រុក្ខជាតិ និងសត្វ។ រីឯធនធានធម្មជាតិមិនកើតឡើងវិញមានដូចជា ធ្យូងថ្ម ប្រេង ឧស្ម័នធម្មជាតិ រ៉ែគ្រប់ប្រភេទរួមមាន សំណ ដែក មាស ត្បូង ស្ពាន់ធ័រ ស័ង្កសី ដីខ្សាច់ ដីឥដ្ឋ...។ ធនធានទាំងអស់នេះ បើយើងជីកយកមកប្រើប្រាស់យូរៗទៅវានឹងអស់។ ឧទាហរណ៍: រ៉ែមាស រ៉ែដែកជាដើម។

## ៣- តើនៅក្នុងបរិវេណសាលារៀន ប្អូនសង្កេតឃើញមានធនធានធម្មជាតិអ្វីខ្លះ ? ចូរកត់ត្រានិងបែងចែកតាមប្រភេទនូវអ្វីដែលប្អូនបានឃើញ។



### ៤- តើនៅក្នុងសហគមន៍របស់ប្អូនមានធនធានធម្មជាតិអ្វីខ្លះ ? ធនធានទាំងនោះផ្តល់សារប្រយោជន៍ដូចម្តេចខ្លះ ?





*ធនធានធម្មជាតិក្នុងសហគមន៍*

ប្រយោជន៍ធនធានធម្មជាតិក្នុងសហគមន៍មានដូចជា៖

- ព្រៃឈើផ្តល់នូវជម្រកសត្វ ដើមឈើធំៗ ផ្តល់ម្លប់ និងអាចយកធ្វើលំនៅដ្ឋាន...
- បឹង ព្រៃលិចទឹកជាជម្រកត្រី បក្សី អាចឱ្យវារស់នៅនិងបន្តពូជ
- ទឹកសម្រាប់ស្រោចដំណាំ និងសម្រាប់មនុស្សសត្វប្រើប្រាស់ដីសម្រាប់ប្រកបរបរដាំដំណាំ ចិញ្ចឹមសត្វផ្សេងៗ ដើម្បីចិញ្ចឹមជីវិតនិងជួយលើកស្ទួយសេដ្ឋកិច្ចគ្រួសារ សហគមន៍ និងសង្គមជាតិ ។ ដូច្នេះមនុស្ស សត្វ រុក្ខជាតិ មិនអាចខ្វះបាននូវធនធានធម្មជាតិទាំងនេះបានឡើយ។

### ៥- ចូរសង្កេតរូបភាពខាងក្រោមនេះ តើបញ្ហាគ្រោះរាំងស្ងួត ខ្យល់ព្យុះ និងទឹកជំនន់បណ្តាលមកពីមូលហេតុអ្វីខ្លះ ?



ប្រសិនបើ មានការបាត់បង់ព្រៃឈើច្រើនហួសហេតុនោះនឹងមានការប្រែប្រួលអាកាសធាតុដូចជាធ្វើឱ្យមាន ខ្យល់ព្យុះ ខ្យល់កន្ត្រាក់ ភាពរាំងស្ងួត កម្តៅនៅលើផែនដីមានការកើនឡើង មានទឹកជំនន់ និងវិនាសបាត់បង់សត្វព្រៃជាដើម។

## ៦- តើប្អូនត្រូវរៀបចំសកម្មភាពអ្វីខ្លះដើម្បីថែរក្សា និងការពារធនធានធម្មជាតិក្នុងសាលារៀន និងសហគមន៍របស់ប្អូនៗ?




ដើម្បីថែរក្សា ការពារ និងអភិរក្សធនធានធម្មជាតិនៅក្នុងសាលារៀននិងក្នុងសហគមន៍ យើងត្រូវ៖

- ប្រើប្រាស់ធនធានធម្មជាតិដោយសន្សំសំចៃ
- កែច្នៃសម្ភារៈដែលប្រើប្រាស់រួច ដើម្បីប្រើប្រាស់សាជាថ្មីទៀត
- កែច្នៃកាកសំណល់ផ្ទះបាយ លាមកសត្វឱ្យទៅជាជីកំប៉ុស្ត
- ចូលរួមយុទ្ធនាការផ្សព្វផ្សាយអំពីការថែរក្សាធនធានធម្មជាតិ និងការគ្រប់គ្រងកាកសំណល់នៅក្នុងសាលារៀននិងសហគមន៍។

១- ចូរញែកប្រភេទធនធានកើតឡើងវិញ និងធនធានមិនកើតឡើងវិញ៖
ពន្លឺព្រះអាទិត្យ ខ្យល់ ឧស្ម័នធម្មជាតិ ទឹក មាស ប្រេង ដី រុក្ខជាតិ ត្បូង សត្វ ថ្ម ភ្នំ និងដែក។

២- ហេតុអ្វីបានជាប្អូនចាំបាច់ត្រូវចូលរួមថែរក្សាធនធានធម្មជាតិ?

៣- តើប្អូនៗរៀបចំផែនការសកម្មភាពបែបណាដើម្បីថែរក្សានិងការពារធនធានក្នុងសហគមន៍?

# មេរៀនទី ២ ជីវៈចម្រុះនិងប្រព័ន្ធអេកូឡូស៊ី

បន្ទាប់ពីបានសិក្សាមេរៀននេះរួច អ្នកសិក្សានឹង៖

- រៀបរាប់ពីប្រភេទផ្សេងៗនៃជីវៈចម្រុះនិងប្រព័ន្ធអេកូឡូស៊ីនៃធនធានធម្មជាតិបានត្រឹមត្រូវ
- ពន្យល់ពីសារប្រយោជន៍នៃជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ីដែលមាននៅក្នុងសហគមន៍
- យល់ថាជីវៈចម្រុះនិងប្រព័ន្ធអេកូឡូស៊ីមានប្រយោជន៍ចំពោះជីវភាពរស់នៅ
- ស្រឡាញ់ និងជំរុញឱ្យមានសកម្មភាពចូលរួមថែរក្សាជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ីដែលមាននៅក្នុងសាលារៀន និងសហគមន៍។

## ១- ចូរសង្កេតរូបភាពខាងក្រោម តើរូបទាំងនេះបង្ហាញពីអ្វី ? តើជីវៈចម្រុះមានន័យដូចម្ដេច ?

*ជីវៈចម្រុះ សំដៅដល់ជីវិតសម្បូរបែបខុសៗគ្នាទាំងឡាយដែល រស់នៅក្នុងតំបន់ដូចគ្នា ឬផ្សេងគ្នានៅលើភពផែនដីដែលមានអន្តរអំពើជាមួយគ្នា រួមមាន រុក្ខជាតិ មីក្រូសារពាង្គកាយ និង សត្វប្រមាណ១០លានប្រភេទ។ ឧទាហរណ៍: ផ្សិត វល្លិ៍ សត្វល្អិត ដង្កូវ ល្មូន សត្វស្លាប សត្វព្រៃ ព្រៃលិចទឹក ....។*



## ២- ចូរសង្កេតរូបភាពខាងក្រោម តើរូបនេះបង្ហាញពីអ្វី ? ដូចម្តេចដែលហៅថាប្រព័ន្ធអេកូឡូស៊ី ?



ស្ថានប្រព័ន្ធ ឬប្រព័ន្ធអេកូឡូស៊ី ជាបណ្តុំសារពាង្គកាយមានជីវិត ទាំងអស់រួមមានសត្វ រុក្ខជាតិ និងមីក្រូសារពាង្គកាយផ្សេងទៀត ដែលមានទំនាក់ទំនងគ្នាទៅវិញទៅមករវាងភាវៈមានជីវិត និងភាវៈគ្មាន ជីវិត ក្នុងតំបន់ភូមិសាស្ត្រណាមួយ។

*ប្រព័ន្ធអេកូឡូស៊ី*

## ៣- ចូរសង្កេតមើលរូបភាពខាងក្រោម តើរូបទាំងនោះបង្ហាញពីអ្វីខ្លះ ? តើជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ីមានសារប្រយោជន៍ចំពោះមនុស្សយ៉ាងដូចម្តេច ?









*ជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ី*

អ្វីៗទាំងអស់រួមមាន មនុស្ស សត្វ រុក្ខជាតិ ទឹក ដី បរិយាកាស ដែលមាននៅលើផែនដីបង្កើតបានជាប្រព័ន្ធអេកូឡូស៊ី។ បើសិនជាមានបញ្ហាកើតឡើងចំពោះជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ី នោះសុខភាព និងការរស់នៅរបស់មនុស្សក៏ប្រឈមនឹងគ្រោះថ្នាក់ដូចគ្នា ជាពិសេសការចិញ្ចឹមជីវិតរបស់មនុស្សដែលពឹងអាស្រ័យនឹងធនធានធម្មជាតិ។

មនុស្សពឹងពាក់ទាំងស្រុងទៅលើរុក្ខជាតិនិងសត្វ ពីព្រោះវាផ្តល់នូវចំណីអាហារ ឱសថ សារធាតុគីមី សម្លៀកបំពាក់ លំនៅដ្ឋាន ប្រភពថាមពលសម្រាប់ជាតម្រូវការច្រើនមុខទៀត។ ប្រសិនបើភាវៈគ្មានជីវិតត្រូវបានបំពុលនោះ ភាវៈមានជីវិតនឹងទទួលការគំរាមកំហែង ហើយក៏មិនអាចលូតលាស់តាមបែបលក្ខណៈធម្មជាតិបានដែរ។

## ៤- តើត្រូវរៀបចំសកម្មភាពបែបណាក្នុងការប្រើប្រាស់ និងថែរក្សាជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ីនៅក្នុងសាលារៀន និងក្នុងសហគមន៍របស់ប្អូន?



*ជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ីក្នុងសាលារៀន*

ក្នុងការប្រើប្រាស់និងថែរក្សាជីវៈចម្រុះនិងប្រព័ន្ធអេកូឡូស៊ីនៅក្នុងសាលារៀន និងក្នុងសហគមន៍ យើងត្រូវ៖

- អភិរក្សជីវៈចម្រុះដែលមាននៅក្នុងសាលារៀន និងក្នុងសហគមន៍
- ការរៀបចំសួនជីវៈចម្រុះសម្រាប់សង្គ្រោះជីវិត សិក្សាអំពីជីវិត និងប្រើប្រាស់ជីវៈចម្រុះឱ្យមានសមភាព។

១- ចូររៀបរាប់ពីប្រភេទផ្សេងៗនៃជីវៈចម្រុះនិងប្រព័ន្ធអេកូឡូស៊ី។ ហេតុអ្វីចាំបាច់មានជីវៈចម្រុះ?

២- ពន្យល់ពីប្រយោជន៍នៃជីវៈចម្រុះនិងប្រព័ន្ធអេកូឡូស៊ីនៅក្នុងសាលារៀននិងសហគមន៍ដែលមានទំនាក់ទំនងទៅនឹងការរស់នៅប្រចាំថ្ងៃរបស់មនុស្ស។

៣- ចូរសង្កេតមើលរូបខាងក្រោម៖

ក- តើក្នុងស្ថានប្រព័ន្ធមួយនេះសង្កេតឃើញមានអ្វីខ្លះ?

ខ- តើស្ថានប្រព័ន្ធនេះចែកជាប៉ុន្មានប្រភេទ? មានអ្វីខ្លះ?



## មេរៀនទី ៣

# ការថែរក្សាធនធានធម្មជាតិ

បន្ទាប់ពីបានសិក្សាមេរៀននេះរួច អ្នកសិក្សានឹង៖

- រៀបរាប់ពីវិធីថែរក្សាធនធានព្រៃឈើ មច្ឆជាតិ និងសត្វព្រៃ
- យល់ថាការថែរក្សាធនធានធម្មជាតិមានប្រយោជន៍ចំពោះជីវភាពរស់នៅ
- រៀបចំសកម្មភាពជាក់ស្តែងក្នុងការថែរក្សាធនធានធម្មជាតិ
- ផ្សព្វផ្សាយពីវិធីថែរក្សាធនធានព្រៃឈើ មច្ឆជាតិ និងសត្វព្រៃក្នុងសហគមន៍
- ស្រឡាញ់ និងចូលរួមថែរក្សាធនធានព្រៃឈើ មច្ឆជាតិ និងសត្វព្រៃក្នុងសាលារៀន និងក្នុងសហគមន៍។

### ១- ចូរសង្កេតរូបភាពខាងក្រោមនេះ ហើយសូមផ្តល់គំនិតផ្ទាល់ខ្លួនដោយឆ្លើយសំណួរខាងក្រោម។

**ក- តើមានអ្វីកើតឡើងចំពោះធនធានព្រៃឈើ ?**





**ខ- តើយើងថែរក្សាធនធានព្រៃឈើដូចម្តេច ?**





ដើម្បីថែរក្សាធនធានព្រៃឈើយើងត្រូវៈ

- មិនត្រូវកាប់បំផ្លាញ
- មិនត្រូវដុតព្រៃឈើ
- មិនបង្កឱ្យមានភ្លើងឆេះព្រៃ
- មិនត្រូវគូសឆ្កូត ឬសរសេរលើសំបកដើមឈើ
- ចូលរួមដាំដើមឈើឡើងវិញ
- ចូលរួមថែរក្សាការពារព្រៃឈើដែលមានស្រាប់
- ប្រើប្រាស់ធនធានព្រៃឈើដោយសន្សំសំចៃ
- ចូលរួមសហការផ្តល់ព័ត៌មានជូនសមត្ថកិច្ចអំពីបទល្មើសព្រៃឈើ។

## ២- ចូរសង្កេតរូបភាពខាងក្រោម តើមូលហេតុអ្វីខ្លះដែលបណ្តាលឱ្យមច្ឆជាតិរងការបំផ្លិចបំផ្លាញ។


ស្បៃអូសត្រី


ការបំពុលត្រី


ឧបករណ៍ឆក់ត្រី

ការចូលរួមថែរក្សាធនធានមច្ឆជាតិៈ

- មិនបំពុលទឹក
  - មិនបោះសំរាមចូលទៅក្នុងទឹក
  - មិនបង្ហូរកាកសំណល់ចូលទៅក្នុងទឹក...។
- មិននេសាទខុសច្បាប់ (ការឆក់ ការប្រើអួន...) ដែលនាំឱ្យផុតពូជមច្ឆជាតិ
- មិននេសាទនៅរដូវត្រីពង
- ត្រូវការពារព្រៃលិចទឹកដែលជាជម្រកមច្ឆជាតិគ្រប់ប្រភេទ។

**៣- ចូរសង្កេតរូបភាពខាងក្រោម តើមានប្រភេទសត្វអ្វីខ្លះ? តើយើងត្រូវការពារ និងថែរក្សាធនធានសត្វព្រៃដូចម្ដេច?**




*ធនធានសត្វព្រៃនៅកម្ពុជា*

ការចូលរួមថែរក្សាធនធានសត្វព្រៃ៖
- មិនត្រូវចាប់ សម្លាប់ និងបរិភោគសាច់សត្វព្រៃជាអាហារ
- មិនប្រមូលយកស៊ុតសត្វ និងបំផ្លាញព្រៃឈើដែលជាជម្រកសត្វព្រៃ
- ការពារមិនឱ្យមានភ្លើងឆេះព្រៃ។ល។

៤- ចូរសង្កេតលើរូបខាងក្រោម តើប្អូនត្រូវធ្វើដូចម្តេចដើម្បីការពារថែរក្សាធនធានព្រៃឈើ មច្ឆជាតិ និងសត្វព្រៃ? តើត្រូវបំផុសចលនាដល់មិត្តភក្តិរបស់ខ្លួនឱ្យចូលរួមថែរក្សាធនធានធម្មជាតិទាំងនោះដូចម្តេចខ្លះ?




*ការចូលរួមថែរក្សាការពារធនធានព្រៃឈើ សត្វព្រៃ*

ដើម្បីបំផុសចលនាដល់មិត្តភក្តិយើងត្រូវ៖
- ធ្វើគម្រោងដាំដើមឈើសម្រាប់យកផ្លែ ម្លប់ ធ្វើផ្ទះ ជម្រកសត្វ នៅក្នុងបរិវេណសាលារៀន ឬនៅតាមសហគមន៍
- បន្តការថែរក្សាធនធានដែលមានស្រាប់
- ចូលរួមទប់ស្កាត់ការបំផ្លាញព្រៃឈើ ដំណាំ ត្រី សត្វ ឬធនធានផ្សេងៗ ដែលមាននៅក្នុងសាលារៀន ឬក្នុងសហគមន៍
- ផ្សព្វផ្សាយ និងអប់រំដល់មិត្តភក្តិ បងប្អូន ក្រុមគ្រួសារ ឬសហគមន៍តាមរយៈបណ្តាញព័ត៌មាន ឬធ្វើយុទ្ធនាការផ្សព្វផ្សាយតាមភូមិ ឃុំដោយសហការជាមួយអាជ្ញាធរដែនដី។

## ៥- តើយើងត្រូវធ្វើសកម្មភាពផ្សព្វផ្សាយពីវិធានការ ការពារថែរក្សា ធនធានព្រៃឈើ មច្ឆជាតិ និងសត្វព្រៃដល់សហគមន៍ដូចម្តេច?













*ការចូលរួមថែរក្សាការពារធនធានព្រៃឈើ មច្ឆជាតិ និងសត្វព្រៃ*

ដើម្បីថែរក្សាធនធានធម្មជាតិយើងត្រូវ៖

- គ្រប់គ្រង និងអភិរក្សធនធានធម្មជាតិដែលមាននៅលើដី ក្នុងទឹក និងក្រោមដី
- អប់រំ និងផ្សព្វផ្សាយដល់បុគ្គលម្នាក់ៗ គ្រួសារ និងសហគមន៍ឱ្យយល់ច្បាស់ពីផលវិជ្ជមាននិងអវិជ្ជមានក្នុងការប្រើប្រាស់ធនធានធម្មជាតិដែលមាននៅក្នុងសហគមន៍
- ចូលរួមគោរពច្បាប់ក្នុងការប្រើប្រាស់ធនធានធម្មជាតិ។

## ៦- ចូរសង្កេតរូបភាពខាងក្រោម។ ហេតុអ្វីបានជាយើងចាំបាច់ត្រូវចូលរួមថែរក្សាធនធានធម្មជាតិ ?



*ការចូលរួមថែរក្សាធនធានធម្មជាតិ*

យើងត្រូវចូលរួមថែរក្សាធនធានធម្មជាតិដើម្បីៈ

- កាត់បន្ថយការកើនឡើងកម្តៅភពផែនដី
- ការពារ និងថែរក្សាព្រៃឈើ និងសត្វព្រៃ
- ភាពសុខដុមរបស់មនុស្ស និងសត្វ
- កាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយផ្សេងៗ
- ទាក់ទាញភ្ញៀវទេសចរ។

១- ចូររៀបរាប់សកម្មភាពដែលប្អូនគិតថាជាសកម្មភាពបំផ្លិចបំផ្លាញធនធានព្រៃឈើ មច្ឆជាតិ និងសត្វព្រៃ។

២- ចូររៀបរាប់ពីវិធីការពារធនធានព្រៃឈើ មច្ឆជាតិ និងសត្វព្រៃ។

៣- ហេតុអ្វីប្អូនចាំបាច់ត្រូវចូលរួមថែរក្សា ការពារ ធនធានទាំងនោះ?

៤- ចូរធ្វើផែនការសកម្មភាពក្នុងការការពារថែរក្សាធនធានធម្មជាតិ មច្ឆជាតិ និងសត្វព្រៃ។

៤- ចូរធ្វើសកម្មភាពផ្សព្វផ្សាយពីវិធានការការពារ ថែរក្សាធនធានព្រៃឈើ មច្ឆជាតិ និងសត្វព្រៃដល់សហគមន៍។

ជំពូកទី ២

# កិច្ចគាំពារបរិស្ថាន



- ថាមពលកកើតឡើងវិញ
- ថាមពលអគ្គិសនី
- ការសន្សំសំចៃទឹក
- សំណល់រឹង
- សំណល់រាវ

មេរៀនទី ១

# ថាមពលកើតឡើងវិញ

បន្ទាប់ពីបានសិក្សាមេរៀននេះរួច អ្នកសិក្សានឹងៈ

- រៀបរាប់ពីនិយមន័យ ប្រភេទផ្សេងៗនៃថាមពលកើតឡើងវិញបានត្រឹមត្រូវ
- បង្ហាញពីសារប្រយោជន៍នៃការប្រើប្រាស់ថាមពលកើតឡើងវិញបាន ត្រឹមត្រូវ
- បណ្តុះគំនិតច្នៃប្រឌិត និងយកចិត្តទុកដាក់ក្នុងការប្រើប្រាស់ថាមពលកើតឡើងវិញ សម្រាប់ជីវិតរស់នៅប្រចាំថ្ងៃប្រកបដោយភាពរីកចម្រើន។

## ១- ចូរសង្កេតរូបភាពខាងក្រោម រួចឆ្លើយសំណួរ។ តើថាមពលកើតឡើងវិញជាអ្វី?



*ថាមពលកកើតឡើងវិញ គឺជាថាមពលកើតពីធនធានដែលត្រូវបានបំពេញឡើងវិញដោយធម្មជាតិ មានដូចជា ថាមពលពន្លឺព្រះអាទិត្យ កម្លាំងខ្យល់ ចរន្តទឹក រលកសមុទ្រ ថាមពលកម្ដៅផែនដី ជីវម៉ាស (អុស ធ្យូង) ជីវឧស្ម័ន (ការដុតលាមកសត្វពាហនៈ) ជីវឥន្ធនៈ (ការដុតរុក្ខជាតិដែលដាំ) និងថាមពលចេញពីសារពាង្គកាយមានជីវិត...។*

## ២- ចូរសង្កេតរូបខាងក្រោម រួចប្រាប់ពីសារប្រយោជន៍ និងការប្រើប្រាស់ថាមពលកើតឡើងវិញ។



*ថាមពលដើរដោយចរន្តទឹក*



*ថាមពលដើរដោយចរន្តខ្យល់*



*ថាមពលដើរដោយជីវឥន្ធនៈ*



*ថាមពលដើរដោយពន្លឺព្រះអាទិត្យ*



*ថាមពលដើរដោយជីវឧស្ម័ន*



*ថាមពលដើរដោយជីវម៉ាស*

ជាទូទៅសារប្រយោជន៍នៃថាមពលកើតឡើងវិញបានជួយសម្រួលនិងកាត់បន្ថយការប្រើប្រាស់កម្លាំងកាយ ពេលវេលា ការចំណាយថវិកាលើការដំណើរការ និងសម្រាប់ការថែទាំ កាត់បន្ថយផ្សែងពុល (ការដុតប្រេងឥន្ធនៈ) និងជាពិសេសកាត់បន្ថយការឡើងកម្តៅផែនដី។ល។

## ៣- ចូរសង្កេតរូបខាងក្រោម រួចប្រាប់ពីវិធីប្រើប្រាស់ថាមពលកើតឡើងវិញប្រកបដោយប្រសិទ្ធភាព។





ការប្រើប្រាស់ថាមពលកើតឡើងវិញប្រកបដោយប្រសិទ្ធភាព៖
- ចេះជ្រើសរើសឧបករណ៍ដែលសន្សំសំចៃថាមពលមកប្រើប្រាស់
- ការបំប្លែងពីថាមពលខ្យល់ឱ្យទៅជាថាមពលអគ្គិសនី (ប្រើប្រាស់កង្ហារខ្យល់)។ ថាមពលបែបនេះយើងអាចផលិតបាននៅតាមតំបន់ដែលសម្បូរទៅដោយខ្យល់ ពិសេសតំបន់ភ្នំ ឬសមុទ្រ...
- ការបំប្លែងថាមពលពីកម្ដៅនៃចំហាយទឹកពុះ ឬកម្ដៅដែលបានពីការបញ្ឆេះសីតុណ្ហភាពនៅក្នុងរោងចក្រ (ភាគច្រើនគេអនុវត្តនៅតាមរោងចក្រ។ ឧ.រោងចក្រស្រាបៀរ...)
- ការបំប្លែងថាមពលពន្លឺព្រះអាទិត្យទៅជាថាមពលអគ្គិសនី (ការបង្កើតផ្ទាំងសូឡាសម្រាប់ស្រូបទាញពន្លឺព្រះអាទិត្យ)។ បច្ចុប្បន្នកសិករភាគច្រើនបានប្រើប្រាស់ផ្ទាំងសូឡាសម្រាប់ជំនួយក្នុងការធ្វើកសិកម្ម...។

## ៤- ចូរសង្កេតរូបខាងក្រោម។ តើត្រូវធ្វើអ្វីខ្លះ ដើម្បីផ្សព្វផ្សាយស្ដីពីការប្រើប្រាស់ថាមពលកើតឡើងវិញប្រកបចីរភាពសម្រាប់សហគមន៍របស់យើង ?



*ឧបករណ៍ផលិតអគ្គិសនីបានមកពីកម្លាំងខ្យល់*

ដើម្បីចូលរួមក្នុងការប្រើប្រាស់ថាមពលកើតឡើងវិញប្រកបដោយចីរភាពយើងត្រូវ៖

- ប្រើប្រាស់ចំណេះដឹង ឬអនុវត្តជាក់ស្តែងទុកជាគំរូ
- លើកទឹកចិត្តបងប្អូន ឬសហគមន៍ឱ្យប្រើប្រាស់ថាមពលកើតឡើងវិញ ជួសជុលថែទាំសម្ភារៈសម្រាប់ផលិតថាមពលកើតឡើងវិញ និងសន្សំសំចៃរាល់ការប្រើប្រាស់ថាមពលនេះ
- ផ្សព្វផ្សាយចំណេះដឹងដល់សហគមន៍ តាមរយៈជួបផ្ទាល់ ឬតាមរយៈអាជ្ញាធរដែនដីភូមិ ឃុំ...។

១- តើថាមពលកើតឡើងវិញមានប្រភពមកពីណាខ្លះ? ចូររៀបរាប់។

២- ចូរជ្រើសរើសប្រភពថាមពលខាងក្រោមឱ្យបានត្រឹមត្រូវ។ តើប្រភពណាខ្លះដែលជាប្រភពថាមពលកើតឡើងវិញ?

□ ប្រភពថាមពលដែលបានមកពីវារីអគ្គិសនី

□ ប្រភពថាមពលដែលបានមកពីពន្លឺព្រះអាទិត្យ

□ ប្រភពថាមពលដែលបានមកពីការដុតជីវម៉ាស

□ ប្រភពថាមពលដែលបានមកពីការដុតធ្យូងថ្ម

□ ប្រភពថាមពលដែលបានមកពីការដុតឥន្ធនៈ។

៣- តើថាមពលកើតឡើងវិញមានសារប្រយោជន៍យ៉ាងដូចម្តេចខ្លះ?

៤- ហេតុអ្វីបានជាគេប្រើប្រាស់ថាមពលកើតឡើងវិញក្នុងជីវិតរស់នៅប្រចាំថ្ងៃ?

# មេរៀនទី ២ ថាមពលអគ្គិសនី

បន្ទាប់ពីបានសិក្សាមេរៀននេះរួច អ្នកសិក្សានឹង៖

- រៀបរាប់ពីប្រភពថាមពលអគ្គិសនីបានត្រឹមត្រូវ
- បង្ហាញពីរបៀបប្រើប្រាស់ថាមពលអគ្គិសនីដោយសន្សំសំចៃបានច្បាស់លាស់
- ច្នៃប្រឌិត និងចូលរួមសន្សំសំចៃថាមពលអគ្គិសនីក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។

## ១- ចូរសង្កេតរូបខាងក្រោម រួចបញ្ជាក់។ តើប្រភពផ្តល់ថាមពលអគ្គិសនីសម្រាប់ប្រើប្រាស់មានប្រភពចេញពីអ្វីខ្លះ ?




*ម៉ាស៊ីនភ្លើង*



*ផ្ទាំងសូឡាផលិតអគ្គិសនី*

ប្រភពដែលផ្តល់ថាមពលអគ្គិសនីសម្រាប់ប្រើប្រាស់មានដូចជា៖

- ប្រភពចេញពីម៉ាស៊ីនភ្លើង
- ពន្លឺព្រះអាទិត្យ
- ការដុតធ្យូងថ្ម ប្រេងឥន្ធនៈ
- ចរន្តទឹក
- ចរន្តខ្យល់
- កម្ដៅចេញពីក្នុងដី
- កម្ដៅចេញពីរុក្ខជាតិ។



*រោងចក្រអគ្គិសនីធ្យូងថ្ម*



*ទំនប់វារីអគ្គិសនី*

## ២- ចូរសង្កេតរូបខាងក្រោម រួចឆ្លើយនឹងសំណួរ។

- តើគេប្រើប្រាស់ថាមពលអគ្គិសនីសម្រាប់ធ្វើអ្វីខ្លះ? ចូររៀបរាប់។
- តើប្អូនៗធ្លាប់ប្រើប្រាស់ថាមពលអគ្គិសនីជាមួយនឹងឧបករណ៍អ្វីខ្លះ?






*ការប្រើប្រាស់ថាមពលអគ្គិសនីប្រចាំថ្ងៃ*

ថាមពលអគ្គិសនីមាននាទីយ៉ាងសំខាន់សម្រាប់ដំណើរការអាជីវកម្ម និងប្រើប្រាស់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។ គេប្រើប្រាស់ថាមពលអគ្គិសនីជារៀងរាល់ថ្ងៃ សម្រាប់បំភ្លឺគេហដ្ឋាន ទីសាធារណៈ ដុតកម្តៅ និងប្រើជាមួយនឹងឧបករណ៍អេឡិចត្រូនិចផ្សេងៗ ដូចជា ទូរសព្ទ វិទ្យុ ទូរទស្សន៍ កង្ហារ កុំព្យូទ័រ ម៉ាស៊ីនត្រជាក់។ល។ លើសពីនេះ គេប្រើវានៅតំបន់ទីក្រុង ឬទីប្រជុំជនដែលជាកន្លែងការងារដូចជា រោងចក្រ សហគ្រាសខ្នាតតូច ខ្នាតធំ និងជាផ្នែកមួយដែលមិនអាចខ្វះបាន។

## ៣- ចូរពិនិត្យមើលរូបភាពដោយយកចិត្តទុកដាក់ រួចឆ្លើយនឹងសំណួរខាងក្រោម។

- តើដើម្បីកាត់បន្ថយការចំណាយថវិកាប្រចាំខែលើការប្រើប្រាស់ថាមពល អគ្គិសនី យើងត្រូវធ្វើដូចម្ដេច? (មិនខ្ជះខ្ជាយ ឬប្រើតាមតម្រូវការជាក់ស្តែង)។
- តើរបៀបប្រើប្រាស់ថាមពលអគ្គិសនីដោយសន្សំសំចៃ យើងត្រូវធ្វើដូចម្ដេចខ្លះ? (វិធីសន្សំសំចៃចំពោះឧបករណ៍ប្រើប្រាស់នីមួយៗ)

- ចូរបង្ហាញ ឬចែករំលែកបទពិសោធន៍ផ្ទាល់ខ្លួនអំពីវិធីសន្សំសំចៃថាមពលអគ្គិសនី ដែលបានអនុវត្តក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។




ការប្រើប្រាស់ថាមពលអគ្គិសនីដោយសន្សំសំចៃ គឺជាការអនុវត្តវិធីសាស្ត្រប្រើប្រាស់ថាមពលអគ្គិសនីឱ្យមានប្រសិទ្ធភាព និងសន្សំសំចៃបំផុតដើម្បីផ្តល់ផលចំណេញខាងសេដ្ឋកិច្ច (គ្រួសារ-ជាតិ) និងចូលរួមជួយដល់ផែនដី។ វិធីងាយៗក្នុងការសន្សំសំចៃថាមពលអគ្គិសនី៖

- ការជ្រើសរើសគ្រឿងបរិក្ខារអគ្គិសនីដែលមានគុណភាពខ្ពស់និងស៊ីភ្លើងតិច (ឧទាហរណ៍ អំពូលម៉ែត្រអាចជួយសន្សំសំចៃបាន៧០% បើប្រៀបធៀបនឹងអំពូលប្រភេទផ្សេង)
- បិទកុងតាក់ (ចំហកុងតាក់) ឬផ្តាច់ចរន្តពីឧបករណ៍អគ្គិសនីផ្សេងៗដែលមិនចាំបាច់
- ដកឧបករណ៍ភ្ជាប់ចរន្ត (ដកឌុយ) ចេញភ្លាម នៅពេលឈប់ប្រើប្រាស់
- កាត់បន្ថយបរិមាណប្រើប្រាស់គ្រឿងអេឡិចត្រូនិចឱ្យបានតិចជាងមុនដូចជា ម៉ាស៊ីនត្រជាក់ ម៉ូទ័របូមធូលី និងឧបករណ៍ផ្សេងទៀតដែលត្រូវការថាមពលអគ្គិសនីច្រើន ដូចជា ម៉ាស៊ីនក្រឡុក ចង្ក្រានមីក្រូវ៉េវ ខ្វះអគ្គិសនី រួមទាំងចង្ក្រានកម្តៅ...)

- ការរៀបចំប្រព័ន្ធ ឬបណ្ដាញភ្លើងឱ្យត្រូវតាមបច្ចេកទេសដូចជា ការតខ្សែភ្លើងត្រូវរុំឱ្យជិតជៀសវាងទឹកជ្រាបចូល ដាក់ព្រីភ្លើងនៅកន្លែងជិតហើយស្ងួតការពារជម្រាបទឹក ការតខ្សែភ្លើងតូចចេញពីប្រភពផ្ដល់ថាមពលអគ្គិសនីដែលជាហេតុធ្វើឱ្យបាត់បង់ចរន្តអគ្គិសនី។ល។

១- ចូររៀបរាប់ពីប្រភពអគ្គិសនីសំខាន់ៗនៅក្នុងប្រទេសកម្ពុជា។

២- តើថាមពលអគ្គិសនីដែលប្រើប្រាស់នៅក្នុងផ្ទះ ឬក្នុងសហគមន៍ដែលកូនរស់នៅបានមកពីណា?

៣- ចូរបង្ហាញ ឬចែករំលែកបទពិសោធន៍ផ្ទាល់ខ្លួនពីវិធីសន្សំសំចៃថាមពលអគ្គិសនីដែលបានអនុវត្តក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។

# មេរៀនទី ៣ ការសន្សំសំចៃទឹក

បន្ទាប់ពីបានសិក្សាមេរៀននេះរួច អ្នកសិក្សានឹង៖

- រៀបរាប់ពីប្រភពទឹក របៀបប្រើប្រាស់ទឹក និងរបៀបសន្សំសំចៃទឹកបានច្បាស់លាស់
- អនុវត្តការប្រើប្រាស់ទឹកដោយមានលក្ខណៈសន្សំសំចៃបានត្រឹមត្រូវ
- បណ្ដុះទម្លាប់ និងចូលរួមសន្សំសំចៃក្នុងការប្រើប្រាស់សម្រាប់ជីវភាពរស់នៅប្រចាំថ្ងៃ។

## ១- ចូរសង្កេតរូបខាងក្រោម។ តើទឹកមានប្រភពមកពីណា? ចូររៀបរាប់។



*ប្រភពទឹក និងការសន្សំសំចៃទឹកលើភពផែនដី*

ទឹកជាតម្រូវការចាំបាច់បំផុតរបស់មនុស្ស សត្វ និងរុក្ខជាតិសម្រាប់ជីវិត។ នៅលើផែនដីទាំងមូលត្រូវបានគ្របដណ្ដប់ដោយទឹកប្រហែលពីរភាគបី (៧០%)។ ប៉ុន្តែភាគច្រើន (៩៧%) នៃទឹកទាំងអស់គឺជាទឹកប្រៃដែលមនុស្សមិនអាចប្រើប្រាស់បាន ហើយ២% ទៀតស្ថិតនៅក្នុងទម្រង់ផែនទឹកកកនៅប៉ូលខាងជើង និងប៉ូលខាងត្បូង ដែលធ្វើឱ្យ

បរិមាណទឹកសាបកាន់តែមានតិចតួចបំផុត (ប្រហែល១%) នៅលើផែនដីដែលមនុស្សអាចប្រើប្រាស់បាន។

**២- ចូរសង្កេតរូបខាងក្រោម។ តើទឹកមានសារៈសំខាន់សម្រាប់មនុស្ស សត្វ រុក្ខជាតិដូចម្ដេចខ្លះ? តើប្រភពទឹកណាខ្លះ យើងអាចប្រើប្រាស់បាននៅប្រទេសកម្ពុជា?**









ទឹកជាតម្រូវការចាំបាច់បំផុតរបស់មនុស្ស សត្វ និងរុក្ខជាតិសម្រាប់ទ្រទ្រង់ជីវិត។ ទឹកដែលមនុស្សអាចប្រើប្រាស់បានមានដូចជា ទឹកលើដី ទឹកក្រោមដី ទឹកភ្លៀង និងទឹកកក។

- **ទឹកលើដី៖** អូរ ស្ទឹង ទន្លេ បឹង ថ្លុក ត្រពាំង ស្រះ តំបន់ដីសើម និងអាងទឹកនានា ដូចជាទន្លេមេគង្គ។ល។
- **ទឹកក្នុងដី៖** មានប្រមាណ៩៥%នៃទឹកសាប ដែលស្ថិតនៅតាមប្រហោង ប្រឡោះ ឬស្នាមប្រេះនានានៅក្រោមផ្ទៃដី។

៣- ចូរសង្កេតរូបខាងក្រោម។ ដើម្បីចូលរួមក្នុងការសន្សំសំចៃទឹក តើត្រូវប្រើប្រាស់ទឹកយ៉ាងដូចម្ដេច ?



យើងអាចចូលរួមសន្សំសំចៃទឹកនៅក្នុងគ្រួសារ សាលារៀន កន្លែងធ្វើការ ដើម្បីចូលរួមសន្សំសំចៃទឹកយើង៖

- មិនបើកទឹកចោលនៅពេលលាងសម្អាត លាងដៃ កំពុងដុសធ្មេញ លុបមុខ ឬងូតទឹកជាដើម
- បិទក្បាលរ៉ូប៊ីណេឱ្យជិតកុំឱ្យស្រក់ទឹកចោល
- ផ្លាស់ប្ដូរក្បាលរ៉ូប៊ីណេដែលខូច ជំនួសដោយថ្មី
- កាត់បន្ថយការប្រើប្រាស់ទឹកបើមិនចាំបាច់
- ប្រើប្រាស់ទឹកឡើងវិញនូវទឹកចេញពីការលាងសម្អាត ដែលមិនប្រើប្រាស់សាប៊ូ និងគ្មានសារធាតុពុលដើម្បីស្រោចផ្កា ឬដំណាំ។ល។
- ចូលរួមផ្សព្វផ្សាយ ដល់មិត្តភក្តិ សហគមន៍ និងក្នុងតំបន់ ជាពិសេសត្រូវថែរក្សាប្រភពទឹកឱ្យបានគង់វង្ស និងត្រឹមត្រូវ
- ការប្រើប្រាស់ទឹកដោយសន្សំសំចៃ គឺជាការគ្រប់គ្រងទឹកប្រកបដោយប្រសិទ្ធភាព ផ្ដល់ផលចំណេញសម្រាប់សេដ្ឋកិច្ចគ្រួសារ និងសង្គមជាតិ។

## ៤- ចូរមើលរូបខាងក្រោមដែលបង្ហាញពីការសន្សំសំចៃទឹកនិងការលាងដៃដោយប្រើប្រាស់ទឹកតិចហើយស្អាត។





១- តើទឹកនៅលើផែនដីមានប្រភពមកពីណាខ្លះ? ចូររៀបរាប់។

២- ហេតុអ្វីបានជាយើងទាំងអស់គ្នាចាំបាច់ប្រើប្រាស់ទឹកដោយសន្សំសំចៃ?

៣- ហេតុអ្វីបានជាទឹកមានសារៈសំខាន់សម្រាប់ជីវិតនៅលើផែនដី? ចូរបកស្រាយ។

៤- តើសកម្មភាពណាខ្លះដែលចាត់ទុកជាសការសន្សំសន្សំចៃទឹក?

# មេរៀនទី ៤ សំណល់រឹង

បន្ទាប់ពីបានសិក្សាមេរៀននេះរួច អ្នកសិក្សានឹង៖

- រៀបរាប់ពីប្រភេទនៃសំណល់រឹងបានត្រឹមត្រូវតាមរយៈមេរៀន
- បង្ហាញពីប្រភេទនៃសំណល់រឹង ផលប៉ះពាល់ និងការទុកដាក់សំណល់រឹងបានត្រឹមត្រូវ
- មានទម្លាប់និងយកចិត្តទុកដាក់វេចខ្ចប់សំណល់រឹងដើម្បីទប់ស្កាត់ពីផលប៉ះពាល់របស់វា។

**១- ចូរសង្កេតរូបភាពខាងក្រោមនេះ។ តើសំណល់រឹងជាអ្វី ? តើសំណល់រឹងទាំងនេះមានប្រភពមកពីណា ?**

*សំណល់រឹង គឺជាវត្ថុរឹងទាំងឡាយ ដែលគេលែងប្រើប្រាស់ ។*



*សំណល់រឹង*

សំណល់រឹង មានប្រភពចេញពីលំនៅដ្ឋាន រោងចក្រ ផ្សារ ហាងទំនិញ ភោជនីយដ្ឋាន សណ្ឋាគារ ផ្ទះសំណាក់ អគារការិយាល័យក្រុមហ៊ុន...។

## ២- ចូរសង្កេតរូបភាពខាងក្រោម។ តើសំណល់រឹងមានប្រភេទអ្វីខ្លះ ? តើសំណល់រឹងប៉ះពាល់ដល់សុខភាពមនុស្ស សត្វដូចម្តេចខ្លះ ក្នុងជីវភាពរស់នៅសព្វថ្ងៃ ?



*ប្រភេទនៃសំណល់រឹង*

សំណល់រឹងមានសំណល់ដែលរលួយ (បន្លែ ផ្លែឈើ សាច់សត្វ។ល។) រីឯសំណល់មិនរលួយមានដូចជា ប្លាស្ទិក សំបកកំប៉ុង លោហៈ ក្រដាស កែវ សារធាតុគីមី។ល។ សំណល់រឹងខ្លះអាចយកមកប្រើឡើងវិញ ខ្លះត្រូវយកទៅកែច្នៃ និងផលិតជាថ្មីឡើងវិញ ខ្លះទៀតជាសារធាតុដែលមានផលប៉ះពាល់ដោយប្រយោល (លោហៈ និងប្លាស្ទិក) ខ្លះទៀតមានផលប៉ះពាល់ជាខ្លាំងដោយផ្ទាល់ (ធាតុគីមីពុល ធាតុវិទ្យុកម្ម។ល។) ដែលត្រូវវេចខ្ចប់និងទុកដាក់ឱ្យមានសុវត្ថិភាពបំផុត។

៣- ចូរមើលលើរូបភាពខាងក្រោម។ តើត្រូវធ្វើសកម្មភាពបែបណាខ្លះដើម្បីចូលរួមទប់ស្កាត់ផលប៉ះពាល់ដែលបង្កឡើងដោយសំណល់រឹង? ហេតុអ្វីបានជាយើងចាំបាច់ត្រូវបែងចែកសំណល់ខុសពីគ្នា?




ដើម្បីទប់ស្កាត់ផលប៉ះពាល់ដែលបណ្ដាលមកពីសំណល់រឹង យើងគួរធ្វើការបែងចែក និងទុកដាក់សំណល់ឱ្យបានត្រឹមត្រូវ។ សកម្មភាពដើម្បីចូលរួមទប់ស្កាត់ផលប៉ះពាល់នៃសំណល់រឹង ត្រូវមានផែនការចូលរួមផ្សព្វផ្សាយដល់មិត្តភក្តិ គ្រួសារ សហគមន៍ និងក្នុងតំបន់ឱ្យយល់ពីផលប៉ះពាល់នៃសំណល់រឹង។ យើងចាំបាច់ត្រូវបែងចែកសំណល់រឹងខុសពីគ្នា ពីព្រោះសំណល់រឹងខ្លះអាចកែច្នៃឡើងវិញបាន និងសំណល់រឹងខ្លះទៀតមិនអាចកែច្នៃបានទេ។

៤- ចូរសង្កេតមើលរូបភាពខាងក្រោម រួចបកស្រាយពីអត្ថប្រយោជន៍នៃសំណល់រឹងក្រោយពេលកែច្នៃរួច។



បច្ចុប្បន្ន សំណល់រឹងជាច្រើនត្រូវបានគេប្រមូលយកមកកែច្នៃជាថ្មីសម្រាប់ប្រើប្រាស់ឡើងវិញតាមរូបភាពផ្សេងទៀត។ មុននឹងកែច្នៃជាថ្មី យើងត្រូវរកវិធីដើម្បីប្រើប្រាស់ឱ្យអស់លទ្ធភាពចំពោះសម្ភារៈដែលយើងបោះចោល គឺត្រូវកែច្នៃជារបស់ថ្មីមួយទៀតតាមលទ្ធភាពដែលអាចធ្វើទៅបាន។ ការកែច្នៃជាថ្មី គឺយើងត្រូវញែក ឬដាក់សំណល់ទាំងនោះទៅតាមប្រភេទរបស់វា ដូចមានក្នុងរូបនេះស្រាប់។ រីឯសំណល់ផ្ទះបាយខ្លះទៀត យើងក៏អាចកែច្នៃធ្វើជាជីកំប៉ុស្តបានដែរ។

**៥- ចូរសង្កេតមើលរូបភាពខាងក្រោម រួចរៀបរាប់ពីវិធានការខ្លះៗដើម្បីកាត់បន្ថយសំណល់រឹង?**



បញ្ញត្តិ 5Rs មានដូចជា កាត់បន្ថយ (Reduce) ប្រើប្រាស់ឡើងវិញ (Reuse) និងកំណែច្នៃជាថ្មី (Recycle) បដិសេធការប្រើប្រាស់ (Refuse) រំឭកអ្នកដទៃ (Remind)។

១- តើសំណល់រឹងមានន័យដូចម្ដេច?

២- ហេតុអ្វីបានជាយើងចាំបាច់ត្រូវទុកដាក់សំណល់ឱ្យបានត្រឹមត្រូវ?

៣- តើវានឹងមានផលប៉ះពាល់យ៉ាងដូចម្ដេចខ្លះ ប្រសិនបើយើងមិនបានទុកដាក់សំណល់រឹងតាមប្រភេទនីមួយៗ?

៤- តើប្អូនៗត្រូវធ្វើដូចម្ដេចដើម្បីចូលរួមផ្សព្វផ្សាយពីផលប៉ះពាល់នៃសំណល់រឹង?

មេរៀនទី ៥

# សំណល់រាវ

បន្ទាប់ពីបានសិក្សាមេរៀននេះរួច អ្នកសិក្សានឹង៖

- រៀបរាប់ពីប្រភេទនៃសំណល់រាវនិងផលប៉ះពាល់របស់វាបានច្បាស់លាស់ តាមរយៈមេរៀន
- បង្ហាញពីវិធីទប់ស្កាត់ផលប៉ះពាល់នៃសំណល់រាវបាន
- ចូលរួមក្នុងការទប់ស្កាត់និងកាត់បន្ថយផលប៉ះពាល់នៃសំណល់រាវក្នុងគ្រួសារ និងសហគមន៍។

**១- ចូរសង្កេតមើលរូបភាពខាងក្រោម។ តើសំណល់រាវជាអ្វី? តើសំណល់រាវមានប្រភពមកពីណា?**






*សំណល់រាវ*

សំណល់រាវសំដៅដល់ទឹក សំណល់មានផ្ទុកសារធាតុពុលបរិស្ថានដែលបញ្ចេញពីសកម្មភាពនានា។ សំណល់រាវមានប្រភពចេញពីរោងចក្រ លំនៅដ្ឋាន ភោជនីយដ្ឋាន ផ្សារ ហាងទំនិញ សណ្ឋាគារ ផ្ទះសំណាក់ និងតាមកន្លែងផ្សេងៗទៀត រួមមាន ប្រេងឥន្ធនៈ ថ្នាំពុល ទឹកសាប៊ូ ទឹកនោម លាមក និងសារធាតុគីមីរាវមួយចំនួនទៀត...។

## ២- ចូរសង្កេតរូបភាពខាងក្រោម រួចប្រាប់ពីផលប៉ះពាល់នៃសំណល់រាវទាំងនោះ។







*ផលប៉ះពាល់នៃសំណល់រាវ*

ផលប៉ះពាល់នៃសំណល់រាវបណ្ដាលឱ្យបំពុលទឹក បាត់បង់ពូជត្រី រុក្ខជាតិ សត្វ និងសុខភាពមនុស្ស។ សព្វថ្ងៃសំណល់រាវ បានកំពុងធ្វើឱ្យខូចនូវសោភ័ណ្ឌភាពទីក្រុងនិងលំនៅដ្ឋាន បាត់បង់នូវកំណើនភ្ញៀវទេសចរ និងបានសម្លាប់ជីវិតសត្វទាំងនៅលើគោក និងក្នុងទឹកជាដើម។

## ៣- ចូរប្អូនៗសង្កេតរូបនេះ ហើយបញ្ចេញមតិផ្ទាល់ខ្លួន។ តើទង្វើបែបនេះត្រឹមត្រូវដែរឬទេ ? ហេតុអ្វី ?



*ការបង្ហូរសំណល់រាវចូលប្រភពទឹកស្អាតដោយមិនបានធ្វើការចម្រោះជាមុន*

សកម្មភាពនេះជាទង្វើដែលមិនគួរធ្វើទេ ព្រោះការបង្ហូរសំណល់រាវចូលប្រភពទឹកដោយមិនបានធ្វើការចម្រោះជាមុន។ អាជ្ញាធរត្រូវចាត់វិធានការចំពោះសកម្មភាពទាំងនេះ ដើម្បីកុំឱ្យមានផលប៉ះពាល់ដល់សុខភាពមនុស្ស សត្វ និងរុក្ខជាតិ ក្រោយពីប្រើប្រាស់ទឹកនេះ។

៤- ចូរសង្កេតមើលរូបនេះ ហើយបញ្ចេញមតិផ្ទាល់ខ្លួន។ តើតាមគ្រួសារនីមួយៗគួររៀបចំប្រព័ន្ធចម្រោះមុនបង្ហូរចេញពីគេហដ្ឋានដែរឬទេ? ព្រោះអ្វី? តើយើងត្រូវធ្វើដូចម្តេចដើម្បីទប់ស្កាត់ពីផលប៉ះពាល់នៃសំណល់រាវ?





*រៀបចំប្រព័ន្ធចម្រោះមុនបង្ហូរចេញពីគេហដ្ឋាន*

គ្រួសារនីមួយៗគួររៀបចំប្រព័ន្ធចម្រោះ មុនបង្ហូរចេញពីគេហដ្ឋាននូវសំណល់រាវទាំងនោះ។ ការចូលរួមធ្វើអនាម័យតាមទីសាធារណៈ គឺជាសកម្មភាពដ៏ល្អសម្រាប់ប្រជាពលរដ្ឋទូទៅ។ ដើម្បីទប់ស្កាត់ផលប៉ះពាល់ដែលបណ្តាលមកពីសំណល់រាវ៖

- ធ្វើអនាម័យទីសាធារណៈឱ្យបានស្អាត
- ទុកដាក់និងមិនបង្ហូរសំណល់រាវចោលផ្តេសផ្តាស
- ការរៀបប្រព័ន្ធចម្រោះមុនបង្ហូរចេញពីគេហដ្ឋាន
- បញ្ឈប់សកម្មភាពបង្ហូរប្រេងឥន្ធនៈចូលប្រភពទឹក
- បញ្ឈប់ការបង្ហូរសំណល់រាវចូលប្រភពទឹក ដោយមិនបានចម្រោះជាមុន។

១- តើសំណល់រាវមានអ្វីខ្លះ?

២- តើសំណល់រាវមានផលប៉ះពាល់យ៉ាងដូចម្តេចខ្លះ?

៣- តើប្អូនត្រូវទុកដាក់ សំណល់រាវយ៉ាងដូចម្តេចដើម្បីទប់ស្កាត់ផលប៉ះពាល់ផ្សេងៗ?

៤- តើប្អូនត្រូវចូលរួមធ្វើសកម្មភាពអ្វីខ្លះដើម្បីផ្សព្វផ្សាយ និងទុកដាក់សំណល់រាវក្នុងសហគមន៍?

ជំពូកទី ៣

# ការរស់នៅប្រកបដោយចីរភាព



- អនាម័យតាមទីសាធារណៈ
- ជំងឺបណ្ដាលមកពីកង្វក់បរិស្ថាន

មេរៀនទី ១

# អនាម័យតាមទីសាធារណៈ

បន្ទាប់ពីបានសិក្សាមេរៀននេះរួច អ្នកសិក្សានឹង៖

- រៀបរាប់ពីសកម្មភាព និងប្រយោជន៍នៃការធ្វើអនាម័យតាមទីសាធារណៈបានត្រឹមត្រូវ
- ចូលរួមអនុវត្តអនាម័យតាមទីសាធារណៈបានត្រឹមត្រូវ
- ចូលរួមអនុវត្តអនាម័យតាមទីសាធារណៈ។

**១- ចូរសង្កេតមើលរូបភាពខាងក្រោម។ តើរូបនេះបង្ហាញពីអ្វី ? តើអនាម័យមានន័យដូចម្ដេច ? ហេតុអ្វីបានជាយើងត្រូវមានអនាម័យក្នុងការរស់នៅប្រចាំថ្ងៃ ?**



*អនាម័យក្នុងការរស់នៅប្រចាំថ្ងៃ*

*អនាម័យ គឺជាការអនុវត្តនូវសកម្មភាពដែលមានអំណោយផលដល់ការថែរក្សាសុខភាពនិងការការពារជំងឺ ជាពិសេសតាមរយៈការផឹកស្អាត ហូបស្អាត និងរស់នៅស្អាត។ អនាម័យសំដៅទៅលើ លក្ខខណ្ឌនិងការអនុវត្តដែលជួយថែរក្សាសុខភាព និងការពារការរីករាលដាលនៃជំងឺ។ ដើម្បីមានសុខភាពល្អ យើងត្រូវធ្វើអនាម័យជាប្រចាំតាមរយៈការហូបស្អាត ផឹកស្អាត និងរស់នៅស្អាត។*

## ២- ចូរសង្កេតរូបភាពខាងក្រោមនេះ។ តើរូបនេះបង្ហាញពីអ្វី? ហេតុអ្វីបានយើងត្រូវចូលរួមធ្វើអនាម័យតាមទីសាធារណៈ?

*អនាម័យតាមទីសាធារណៈ គឺជាសកម្មភាពទាំងឡាយណាដែលចូលរួមសម្អាត ថែរក្សា ការពារបរិស្ថាននៅជុំវិញ ទីកន្លែង ដែលខ្លួនកំពុងរស់នៅ។ ដើម្បីឱ្យទីកន្លែងទាំងនោះមានបរិស្ថានល្អ និងមានសោភ័ណភាព។*






*អនាម័យតាមទីសាធារណៈ*

៣- ចូរសង្កេតមើលរូបភាពខាងក្រោម រួចពិភាក្សា។ តើសកម្មភាពបែបណាដែលយើងមិនគួរធ្វើតាមទីសាធារណៈ ? តើការចោលសំរាមពាសវាលពាសកាលនាំមកនូវផលប៉ះពាល់ដូចម្ដេចខ្លះ ?



*លទ្ធផលនៃការគ្មានអនាម័យតាមទីសាធារណៈ*

ទីសាធារណៈដែលគ្មានអនាម័យនាំឱ្យបរិស្ថានមិនស្អាត គ្មានសោភ័ណ មានសំរាម មានក្លិនស្អុយ មានភ្នាក់ងារបង្ករោគនាំឱ្យកើតជំងឺ។ល។ ការចោលសំរាមពាសវាលពាសកាល ដោយមិនបានរៀបចំទុកឱ្យត្រឹមត្រូវបង្កនូវផលប៉ះពាល់បរិស្ថានយ៉ាងខ្លាំង និងជាពិសេសប៉ះពាល់ដល់សុខភាព។

### ៤- ចូរសង្កេតមើលរូបភាពខាងក្រោម រួចពិភាក្សាពីផែនការសកម្មភាពបែបណា ដែលប្អូនគួរធ្វើតាមទីសាធារណៈ។



*លទ្ធផលនៃការអនាម័យតាមទីសាធារណៈ*

ដើម្បីឱ្យទីសាធារណៈមានអនាម័យ សោភ័ណភាព យើងត្រូវចូលរួមថែរក្សាបរិស្ថាន តាមរយៈការចូលរួមសម្អាតបរិស្ថាន ទុកដាក់សំរាមក្នុងធុងសំរាមឱ្យបានត្រឹមត្រូវ មិនត្រូវចោលសំរាមពាសវាលពាសកាល មិនត្រូវបន្ទោបង់ពាសវាលពាសកាលតាមទីសាធារណៈ...។

១- តើប្អូនៗត្រូវធ្វើអ្វីខ្លះ ដើម្បីធ្វើអនាម័យតាមទីសាធារណៈ?

២- តើប្អូនៗត្រូវអនុវត្តផែនការសកម្មភាពអ្វីខ្លះ ដើម្បីធ្វើអនាម័យតាមទីសាធារណៈ?

៣- តើឥទ្ធិពលអនាម័យតាមទីសាធារណៈមានទំនាក់ទំនងនឹងជីវិតប្រចាំថ្ងៃដូចម្ដេច? ចូររៀបរាប់។

៤- តើត្រូវធ្វើដូចម្ដេចដើម្បីបណ្ដុះស្មារតីមនុស្សគ្រប់គ្នាឱ្យចូលរួមអនាម័យនៅតាមទីសាធារណៈ?

# មេរៀនទី ២ ជំងឺបណ្ដាលមកពីកង្វក់បរិស្ថាន

បន្ទាប់ពីបានសិក្សាមេរៀននេះរួច អ្នកសិក្សានឹងៈ

- រៀបរាប់ពីប្រភេទជំងឺនិងការបង្ការនៃជំងឺដែលបណ្ដាលមកពីកង្វក់បរិស្ថានបានច្បាស់លាស់
- ពន្យល់និងចូលរួមអនុវត្តវិធីបង្ការជំងឺបណ្ដាលមកពីការប៉ះពាល់បរិស្ថានបានត្រឹមត្រូវ
- ចូលរួមណែនាំ និងអនុវត្តវិធីបង្ការជំងឺ បណ្ដាលមកពីកង្វក់បរិស្ថានក្នុងគ្រួសារ និងសហគមន៍។

## ១- ចូរមើលរូបភាពខាងក្រោម។ តើមានជំងឺអ្វីខ្លះដែលបណ្ដាលមកពីកង្វក់បរិស្ថាន? ចូររៀបរាប់ពីប្រភេទនៃជំងឺដែលបណ្ដាលមកពីកង្វក់បរិស្ថាន។




*ជំងឺបណ្ដាលមកពីកង្វក់បរិស្ថាន*

ជំងឺបណ្ដាលមកពីកង្វក់បរិស្ថាន មាន៣ផ្នែកធំៗគឺៈ

- ជំងឺបណ្ដាលមកពីការបំពុលទឹក
- ជំងឺបណ្ដាលមកពីសំណល់រឹង
- ជំងឺបណ្ដាលមកពីដុតសំរាមបំពុលខ្យល់។

## ២- ចូរសង្កេតរូបខាងក្រោម។ តើសកម្មភាពបែបណាខ្លះដែលចាត់ទុកថាជាការបំពុលទឹក? តើការបំពុលទឹកមានផលប៉ះពាល់ដល់សុខភាពមនុស្សយ៉ាងដូចម្ដេច?



*ជំងឺបណ្ដាលមកពីការបំពុលទឹក*

ជំងឺបណ្ដាលមកពីការបំពុលទឹក៖

- បង្កពីមីក្រូសារពាង្គកាយ និងសារធាតុគីមីនៅក្នុងទឹក ដូចជាជំងឺរាគ អាសន្នរោគ គ្រុនពោះវៀន
- ជំងឺកម និងរមាស់ពីការប៉ះពាល់ទឹកកខ្វក់។ល។
- មនុស្សភាគច្រើនកំពុងធ្វើសកម្មភាពដែលនាំឱ្យកង្វក់ដល់បរិស្ថាន ដោយមិនដឹងខ្លួន ពិសេសគឺការបំពុលទឹក។

## ៣- ចូរសង្កេតរូបភាពខាងក្រោម។ តើសត្វទាំងនេះបង្កនូវផលវិបាកអ្វីខ្លះដល់សុខភាព?

*ភ្នាក់ងារចម្លងជំងឺមានដូចជា រុយ កណ្ដុរ និងមូស...។ ភ្នាក់ងារទាំងនេះបង្កជាជំងឺរាគរូស ក្អួតចង្អោរ អាសន្នរោគ គ្រុនចាញ់ គ្រុនពោះវៀន គ្រុនឈាម...។*



## ៤- ចូរសង្កេតរូបភាពខាងក្រោម រួចប្រាប់ពីផលប៉ះពាល់នៃការបំពុលខ្យល់។




*ជំងឺបណ្ដាលមកពីការបំពុលខ្យល់*

ជំងឺបណ្ដាលមកពីការដុតសំរាមបំពុលខ្យល់៖

- ការដុតសំរាម បង្កឱ្យមានសារជាតិពុលល្អិតឆ្មារៗ ហើរតាមខ្យល់បង្កផលប៉ះពាល់ខ្លាំងដល់ប្រព័ន្ធផ្លូវដង្ហើម រលាកទងសួត និងជំងឺហឺត
- ការដុតសំរាមបានបញ្ចេញជាតិលោហៈធ្ងន់ដូចជា លីតូនីញ៉ូម សំណ ដែលជាភ្នាក់ងារបង្កជំងឺមហារីកផ្លូវដង្ហើម។

## ៥- ចូរសង្កេតរូបទាំងនេះ រួចពិភាក្សាតាមក្រុមតូចៗ ហើយកត់ត្រានូវវិធានការដើម្បីបង្ការជំងឺដែលបណ្ដាលមកពីកង្វក់បរិស្ថាន។




*ការអនុវត្តវិធានការដើម្បីគ្រួសារ សហគមន៍គ្មានកង្វក់បរិស្ថាន*

ការបង្ការជំងឺបណ្ដាលមកពីកង្វក់បរិស្ថាន។ ដើម្បីចូលរួមណែនាំ និងអនុវត្តវិធីបង្ការជំងឺបណ្ដាលមកពីកង្វក់បរិស្ថានក្នុងគ្រួសារ និងសហគមន៍ យើងត្រូវ៖

- បង្ការកុំឱ្យរុយរោមអាហារតាមការប្រើសាជីគ្របជាដើម
- ប្រើប្រាស់បង្គន់អនាម័យឱ្យបានត្រឹមត្រូវ
- រក្សាអនាម័យខ្លួនប្រាណ និងផ្ទះសម្បែង
- បរិភោគទឹកដាំពុះ ឬទឹកស្អាត
- ទុកដាក់សំបកកំប៉ុង កង់ឡាន ម៉ូតូឱ្យបានត្រឹមត្រូវ ដើម្បីកំចាត់ប្រភពមូស
- មានឆន្ទៈចូលរួមកាត់បន្ថយសំរាមនិងប្លាស្ទិក ចូលរួមកម្មវិធីបរិស្ថានផ្សេងៗ។

១- ចូររៀបរាប់ពីប្រភេទជំងឺដែលបណ្ដាលមកពីកង្វក់បរិស្ថាន។

២- ហេតុអ្វីបានជាចាំបាច់មានវិធានការលើកង្វក់បរិស្ថាន?

៣- តើត្រូវអនុវត្តវិធីបង្ការជំងឺដែលបណ្ដាលមកពីកង្វក់បរិស្ថានយ៉ាងដូចម្ដេច?

៤- តើអ្នកត្រូវធ្វើដូចម្ដេច ដើម្បីចូលរួមបង្ការជំងឺបណ្ដាលមកពីកង្វក់បរិស្ថាន?

CAMBODIA CLIMATE CHANGE ALLIANCE

Implemented by:

Funded by:

ស៊ុយអែត
Sverige